គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ភ្នំពេញ, ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៣

# លទ្ធផលវេទិកា នៅខេត្តកំពង់ឆ្នាំង
## "កំណែទម្រង់ការបោះឆ្នោត និងលំហរប្រជាធិបតេយ្យនៅកម្ពុជា"

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ក្រោមកិច្ចសហការជាមួយបណ្ដាអង្គការ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានរៀបចំវេទិកាមួយ ស្ដីអំពី "**កំណែទម្រង់ការបោះឆ្នោត និងលំហរប្រជាធិបតេយ្យនៅកម្ពុជា (FOREDS)**" នៅ **ខេត្តកំពង់ឆ្នាំង** កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣ ដោយមានការចូលរួមពីតំណាងគណបក្សនយោបាយ តំណាងគ.ជ.បខេត្ត អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធប្រមាណ **១១០នាក់**។

វេទិកានេះរៀបចំឡើងក្នុងគោលបំណង ដើម្បីឲ្យភាគីដែលពាក់ព័ន្ធបានលើកឡើង និងជជែកពីបញ្ហាដែលទាក់ទងទៅនឹងការបោះឆ្នោត និងប្រជាធិបតេយ្យនៅកម្ពុជា ហើយស្វែងរកនូវអនុសាសន៍ គោលនយោបាយដែលបានពិភាក្សាចែកជូនដល់អ្នកចូលរួម និងបញ្ជូនអនុសាសន៍ទាំងនោះទៅស្ថាប័នដែលពាក់ព័ន្ធក្នុងការដោះស្រាយ។

| **អនុសាសន៍ពី វេទិកា** FOREDS **នៅខេត្តកំពង់ឆ្នាំង** (**ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣**) |
|---|
| **១. ការជ្រើសរើស និងការពង្រឹងសមត្ថភាពមន្ត្រីបោះឆ្នោតនៅថ្នាក់ឃុំ និងថ្នាក់ការិយាល័យបោះឆ្នោត**<br>• បង្កើតគណៈកម្មការចម្រុះមកពីគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភាចូលរួមត្រួតពិនិត្យ និងជ្រើសរើសបេក្ខជន CEC និង PSO<br>• ជ្រើសរើសបុគ្គលិកដែលមានបទពិសោធន៍ ៧0% និងគ្មាន៣0%<br>• ឋានានុក្រម CEC និង PSO គួរតែមានសមាសភាពឯករាជ្យ<br>• គ្រប់ការិយាល័យបោះឆ្នោត ការរាប់សន្លឹកឆ្នោត (ធ្វើនៅកន្លែងណា រាប់កន្លែងនោះ)<br>• ការបណ្ដុះបណ្ដាលត្រឹមត្រូវឲ្យមានភាពស៊ីជំរៅ (ក្នុងរយៈពេល ២ថ្ងៃ ) សូមស្នើសុំថវិកា ក្នុង១ថ្ងៃ យ៉ាងតិច ៤0.000 រៀល សម្រាប់បណ្ដុះបណ្ដាល (តាមឋានានុក្រម)។ |
| **២. ការទប់ស្កាត់ និងបង្ការអំពើហិង្សាពេលបោះឆ្នោត**<br>**ដំណោះស្រាយ គឺពង្រឹងការអនុវត្តន៍ទៅលើក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធទៅនឹងបញ្ហាខាងក្រោម៖**<br>• ត្រូវមានចិត្តអត់ធ្មត់នៅពេលបោះឆ្នោត<br>• មិនបំពានលើគណបក្សដទៃ<br>• ត្រូវអនុវត្តតាមសេចក្ដីណែនាំនៃច្បាប់បោះឆ្នោត |

ទីស្នាក់ការកណ្ដាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

- មិនឈ្លោះប្រកែកគ្នា និង បង្ករបួសស្នាមនៅពេលបោះឆ្នោត
- គោរពសិទ្ធិគ្នាទៅវិញទៅមកនៅពេលបោះឆ្នោត
- ត្រូវមានក្រមសីលធម៌នៅពេលឃោសនាបោះឆ្នោត
- ត្រូវមានភាពអព្យាក្រឹត្យ និងយុត្តិធម៌នៅពេលបោះឆ្នោត
- មិនប្រកាន់បក្សពួកនិយមនៅពេលបោះឆ្នោត
- មិនត្រូវយកគ្រឿងអាវុធចូលការិយាល័យបោះឆ្នោត
- មិនត្រូវយកអំណាចមកគាបសង្កត់ដល់អ្នកមានសិទ្ធិបោះឆ្នោត
- មិនត្រូវរារាំងដល់អ្នកបោះឆ្នោតឡើយ
- មិនត្រូវប្រើគ្រឿងស្រវឹង និងបង្ករបួសស្នាមនៅពេលបោះឆ្នោត
- ប្រសិនជាមានអំពើហិង្សាទាំងអស់នេះកើតឡើង យើងត្រូវរកសមត្ថកិច្ចជួយដោះស្រាយទាន់ពេលវេលា
  - ពង្រឹងការអនុវត្តន៍នីតិវិធីដែលមានស្រាប់ដោយ គ.ជ.ប
  - ធ្វើឲ្យមានអព្យាក្រឹត្យភាពដល់ភ្នាក់ងាររអាជ្ញាធរ និងមេភូម និងអនុប្រធានភូមិ
  - ឲ្យមានការបណ្តុះបណ្តុះបណ្តាល រាល់បទដ្ឋានដែលទាក់ទងជូនដល់មេភូមិ និងគណនបក្សនយោបាយ
  - និង ពង្រឹងការអនុវត្តន៍នូវរាល់បទដ្ឋាន និងនីតិវិធីទាំងនេះ។

**៣. ដំណោះស្រាយបណ្តឹងទាក់ទងទៅនឹងការបោះឆ្នោត**

- ត្រូវពង្រឹងសមាសភាពរបស់ គ.ជ.ប ឲ្យត្រូវតែអព្យាក្រឹត្យ ដាច់ខាតដោយគ្មានការពាក់ព័ន្ធនៅក្នុងគណបក្សនយោបាយ
- សមាជិករបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែមិនមែនជាសមាជិករបស់គណបក្សនយោបាយ
- គ.ជ.ប និងក្រសួងមហាផ្ទៃសហការគ្នាបង្កើត និងអនុវត្តទោសបញ្ញត្តិ សំរាប់ដោះស្រាយបណ្តឹងទាក់ទងទៅនឹងការបោះឆ្នោត (ដល់មន្ត្រីធ្វើខុសច្បាប់)
- សូមជួយផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ ឲ្យយល់ច្បាស់អំពីច្បាប់របស់ គ.ជ.ប នៅពេលរៀបចំការបោះឆ្នោត

**៤. សេរីភាពក្នុងការបញ្ចេញមតិ និងប្រមូលផ្តុំ**

- សូមឲ្យប្តូរការិយាល័យបោះឆ្នោតណាដែលមានទីតាំងស្ថិតនៅជាប់ ឬក្បែផ្ទះរបស់អាជ្ញាធរ
- នៅពេលមានការប្រជុំសម្រេចអ្វីមួយ សូមកុំឲ្យមានការរើសអើង និងបដិសេធពីអាជ្ញាធរ
- បង្កើតឲ្យមានវេទិកាសាធារណៈនៅទីកន្លែងប្រជុំជន និងតាមបណ្តា ស្រុក ឃុំ
- ភាពមិនយុត្តិធម៌ ក្នុងការប្រកួតប្រជែងក្នុងការបោះឆ្នោត
- ចង់បាននីតិវិធីធ្វើច្បាប់យ៉ាងណាដើម្បីឲ្យមានការពារក្នុងការបញ្ចេញមតិ
- ចង់បានវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីសិទ្ធិដល់សហគមន៍
- សូមផ្លាស់ប្តូរ គ.ជ.ប ពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម
- សូមឲ្យអង្គការសង្គមស៊ីវិល មានសិទ្ធិចូលរួមជាយោបល់គាំទ្រពីបញ្ហា
  និងតម្រូវការរបស់ប្រជាពលរដ្ឋ ដោយមិនមានការចោទប្រកាន់ថាអង្គការសង្គមស៊ីវិលជាអ្នកញុះញង់។
- សូមឲ្យមន្ត្រីប៉ូលីស កងកម្លាំងប្រដាប់អាវុធមានភាពអព្យាក្រឹត្យ

| |
|---|
| • សូមឲ្យតំណាងភ្នាក់ងារអង្កេតការណ៍បោះឆ្នោតមានសិទ្ធិចល័តក្នុងការបោះឆ្នោត។ |
| **៥. ហិរញ្ញវត្ថុគណបក្សនយោបាយ**<br>• សុំឲ្យមានច្បាប់ស្ដីពីហិរញ្ញវត្ថុនយោបាយ<br>• ស្ថាប័ន គ.ជ.ប ជាអ្នកត្រួតពិនិត្យការចំណាយរបស់គណបក្សនីមួយៗ<br>• បើសភា ឬរដ្ឋកំណត់ សូមឲ្យកំណត់យ៉ាងតិចបំផុតដើម្បីឲ្យរដ្ឋសល់ថវិកាច្រើន<br>• ស្នើសុំរាជរដ្ឋាភិបាលកំណត់ចាយថវិកាស្មើគ្នាតាម ឃុំ-សង្កាត់នីមួយៗ ដើម្បីចាញ់អស់ចិត្ត ឈ្នះអស់ចិត្ត<br>• សំណូមពរឲ្យស្ថាប័ន គ.ជ.ប ជាអ្នកត្រួតពិនិត្យ គ.ជ.ប ទាល់តែត្រឹមត្រូវហើយយុត្តិធម៌ទៀត (ថវិកាជាតិ ឬថវិកាឯកជន) ហើយសង្គមស៊ីវិលមានការចូលរួមផងក្នុងការចាយវាយថវិកា |

<u>*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង*</u> *៖*

*១-លោក **សួន យុព្យា** / មន្ត្រីតស៊ូមតិ និងច្បាប់ខុមហ្វ្រែល (០៩៧-៥៩-៨៧-២៦៥)*

<u>*បេសកកម្ម*</u> *៖* បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ **ទី១**/ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌ តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្ដល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្ដល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក **ទី២**/ ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្ដីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្ដល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ ការងាររបស់មន្ត្រីជាប់ឆ្នោត។